ក្រសួងបរិស្ថាន
លេខ: ៦៤៣ ...ប.ស្ត

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃការវាយតម្លៃលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ១៦ នៅក្នុងខេត្តមណ្ឌលគិរី រតនគិរី និងកំពង់ស្ពឺក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានមានកិត្តិយស សូមជម្រាបជូនដល់សាធារណជនឱ្យបានជ្រាបថា កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន ១៦ ដែលទទួលបានសិទ្ធិវិនិយោគលើផ្ទៃដីសរុប **៩៦ ០៩៨ ហ.ត** ក្នុងនោះ នៅខេត្តមណ្ឌលគិរីមានចំនួន ៥ ក្រុមហ៊ុន ដែលទទួលបានសម្បទានដីសេដ្ឋកិច្ច នៅតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃភ្នំណាមលៀរ ដែនជម្រកសត្វព្រៃភ្នំព្រេច នៅខេត្តរតនៈគិរីមានចំនួន ៤ ក្រុមហ៊ុន ដែលទទួលបានសម្បទានដីសេដ្ឋកិច្ច នៅដែនជម្រកសត្វព្រៃលំផាត់ និងក្នុងខេត្ត កំពង់ស្ពឺមានចំនួន ៧ ដែលទទួលបានសម្បទានដីសេដ្ឋកិច្ចនៅតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងឧទ្យានជាតិសុរាម្រិត-កុសុមៈ គិរីរម្យ បន្តអនុវត្តគម្រោងនិងបំពេញនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ដោយត្រូវចុះកិច្ចសន្យាឡើងវិញ និងកាត់បន្ថយរយៈពេលនៃការវិនិយោគដែលផ្តល់ឱ្យពីមុនមកមាន ៩៩ ឆ្នាំ ៨០ ឆ្នាំ និង ៧០ ឆ្នាំឱ្យមក នៅត្រឹមរយៈ ពេល ៥០ ឆ្នាំវិញ។ សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចជាគោលការណ៍ ក្នុងការកាត់បន្ថយរយៈពេលនៃការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចទាំងអស់មកនៅត្រឹមយ៉ាងយូរ ៥០ ឆ្នាំ។

ក្រសួងបរិស្ថានសូមរំលឹកថា រហូតមកទល់ពេលនេះ ក្រសួងបានពិនិត្យ និងវាយតម្លៃគម្រោងវិនិយោគអភិវឌ្ឍន៍ទាំងអស់ចំនួនសរុប ១១៣ ដែលមានផ្ទៃដីសរុប **៦២៨ ២៩៨,៧៥ ហ.ត** ដែលក្នុងនោះគម្រោងចំនួន ៨១ ត្រូវបានដាក់ឆ្លងអង្គប្រជុំគណៈកម្មាធិការអន្តរក្រសួងដើម្បីពិភាក្សា និងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេច ហើយជាលទ្ធផលគម្រោងរបស់ក្រុមហ៊ុនចំនួន ២៣ ដែលមានផ្ទៃដីសរុប **៩០៦៨២ ហ.ត** ត្រូវបានរាជរដ្ឋាភិបាលសម្រេចនិរាករណ៍ (ដកហូត) សិទ្ធិវិនិយោគដោយសារតែក្រុមហ៊ុនទាំងនោះ មិនបានគោរពតាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់។ ចំណែកឯគម្រោងចំនួន ៤ ដែលមានផ្ទៃដីសរុប **៣២ ២៨៧ ហ.ត** ត្រូវបានក្រុមហ៊ុនប្រគល់ដោយស្ម័គ្រចិត្តឱ្យរាជរដ្ឋាភិបាលគ្រប់គ្រងវិញ រីឯគម្រោងចំនួន ៤ ផ្សេងទៀតដែលមានផ្ទៃដីសរុប **១៤៨៥៤,៧៥ ហ.ត**

ត្រូវបានរាជរដ្ឋាភិបាលកាត់បន្ថយទំហំផ្ទៃដីវិនិយោគ មកត្រឹម **១២៦២ ហ.ត** និងគម្រោងចំនួន១៨ ដែលមានផ្ទៃដីសរុប **១០១ ៣៦០ ហ.ត** ត្រូវបានរាជរដ្ឋាភិបាលទុកពេលឱ្យពី ៦ ខែទៅ ១ឆ្នាំ ដើម្បីបន្តនីតិវិធីចាំបាច់នានាដោយស្ថិតក្រោមការតាមដានរបស់ក្រសួងបរិស្ថាន។

ចំពោះគម្រោងចំនួន ១៦ ផ្សេងទៀត ដែលមានផ្ទៃដីសរុប **៧៦ ២៧៩ ហ.ត** ដែលបានដាក់ឆ្លងគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែងនិងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចរួចហើយ ប៉ុន្តែមិនទាន់សម្រេច គណៈកម្មការអន្តរក្រសួង គ្រោងនឹងលើកករណីនេះមកដាក់ ក្នុងកិច្ចប្រជុំពិភាក្សាជាថ្មីម្តងទៀត ដើម្បីសម្រេចជាចុងក្រោយ មុននឹងស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ ចំពោះគម្រោង ៣២ ដែលនៅសេសសល់ដែលមានផ្ទៃដីសរុប **២១៦ ៧៣៨ ហ.ត** ក្រសួងបរិស្ថានបានពិនិត្យ និងវាយតម្លៃ និងធ្វើរបាយការណ៍ទៅកាន់គណៈកម្មការក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច រួចហើយ រង់ចាំតែដាក់ឆ្លងអង្គប្រជុំគណៈកម្មការអន្តរក្រសួងតែប៉ុណ្ណោះ។ ក្រសួងគ្រោងនឹងបញ្ចប់កិច្ចការត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងទាំង នេះនៅក្នុងពេលវេលាសមស្របខាងមុខ។ ការត្រួតពិនិត្យ វាស់វែង និងវាយតម្លៃគម្រោងសម្បទានដីសេដ្ឋកិច្ចឡើងវិញនេះពិតជាមានសារៈសំខាន់ណាស់ ដើម្បីគ្រប់គ្រងឱ្យមានប្រសិទ្ធភាព លើសម្បទានដីសេដ្ឋកិច្ចដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន បំណងដើម្បីផ្តល់ភាពកក់ក្តៅដល់អ្នកវិនិយោគទុន ក៏ដូចជាដោះស្រាយ លើផលប៉ះពាល់ទាំងឡាយឱ្យបានត្រឹមត្រូវនិងកំណត់ច្បាស់ថា សម្បទានដីសេដ្ឋកិច្ចទាំងអស់នឹងមិនមានការប៉ះពាល់ដល់ដីធ្លីរបស់ប្រជាពលរដ្ឋឡើយ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង*

ឯកឧត្តម ស្រ៊ុន ដារិទ្ធិ នាយខុទ្ទកាល័យក្រសួងបរិស្ថាន

ទូរស័ព្ទ៖ ០១២ ៤៤៨ ៤៤៤

អ៊ីម៉ែល៖ srundarith@gmail.com